គម្រោងបន្ទាញបច្ចេកវិទ្យាដើម្បីបង្កើន ផលិតភាព ជុំវិញតំបន់ទន្លេសាប

TSTD (ADB TA 7305-CAM)

# បច្ចេកទេសចិញ្ចឹមត្រីចម្រុះ



## ទីតាំងទំនាក់ទំនងទិញកូនត្រីពូជ

ខេត្តកំពង់ចាម
- បាធាយ: ញ៉ែម ពេញ ០៨៨ ៩០ ១០ ៤៩៦
- ជើងព្រៃ: អ៊ិន ប៊ុក ០៩៧ ៣០ ៥២ ៣៩១

ខេត្តកំពង់ធំ
- ស្ទឹងសែន: កង សម្បត្ត ០១៧ ២៧ ២២ ៨៧
- ស្ទោង: គឹង គា ០៩២ ៦៨ ៩២ ៥៧

ខេត្តបន្ទាយមានជ័យ
- សិរីសោភ័ណ្ឌ: គាត សុណាន ០៨៨៩១៥៧៦៦១

ស្រុកអូរជ្រៅ: យឹម ភាត់ ០៨៩ ៦២ ០៨ ៥៨

ខេត្តសៀមរាប
- សូទ្រនិគម: ស៊ាយ ប៊ុក ០៨៨ ៥៩៩ ៧០ ៩៧
- សៀមរាប: សេង អាន ០៩៦ ២៦៣ ៥៧ ៥៧

ឧបត្ថម្ភថវិកាដោយ:

រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និង ធនាគារអភិវឌ្ឍន៍អាស៊ី

ខែ មេសា ឆ្នាំ ២០១៣

## សេចក្តីផ្តើម

ការចិញ្ចឹមត្រីចម្រុះក្នុងស្រះ គឺជារបៀបចិញ្ចឹមមួយដែលធ្វើឱ្យអ្នកចិញ្ចឹម បានចំណេញច្រើន ដោយសារចំណីដែលបានផ្តល់ឱ្យត្រី ត្រូវបានត្រីពីរ ឬ ច្រើនប្រភេទ ស៊ីអស់ ព្រោះប្រភេទត្រីបានជ្រើសរើសចិញ្ចឹម មានចរិតស៊ីចំណីខុសៗគ្នា គឺថា ត្រីប្រភេទខុសគ្នា ស៊ីចំណីនៅស្រទាប់ទឹកខុសគ្នា និង ស៊ីចំណីប្រភេទខុសគ្នា។

ជាទូទៅ ប្រភេទត្រីដែលគេចិញ្ចឹមចម្រុះភាគច្រើន ជាប្រភេទត្រី ដែលស៊ីទាំងចំណីធម្មជាតិ និង ចំណីបន្ថែម ។ ត្រីទាំងនេះ មាន ត្រីឆ្ពិន ត្រីទីឡាព្យា ត្រីព្រលូង ត្រីកាប...។

## គុណសម្បត្តិនៃការចិញ្ចឹមត្រីចម្រុះ

✧ប្រើចំណីបន្ថែមអស់តិច បានផលត្រីច្រើន ដោយសារមានប្រភេទត្រីមួយចំនួន ស៊ីចំណីធម្មជាតិដែលជានិច្ចកាលតែងតែកើតមានក្នុងទឹក។

✧ធ្វើឱ្យទឹកស្រះរក្សាគុណភាពល្អបានយូរ ព្រោះប្រភេទត្រីចម្រុះ បានស៊ីអស់លទ្ធភាពនូវចំណីដែលបានផ្តល់ឱ្យដែលជាហេតុធ្វើឱ្យទឹក មិនងាយស្អុយ។

✧ការចិញ្ចឹមត្រីចម្រុះ ផ្តល់ភាពសមស្រមច្រើនសម្រាប់កសិករដែលមិនសូវមានលទ្ធភាពទិញចំណី បានគ្រប់គ្រាន់ និង មិនមានលទ្ធភាពផ្លាស់ប្តូរទឹក។



## តើត្រូវការបច្ចេកទេសអ្វីខ្លះដើម្បីទទួលបានជោគជ័យ ?

### ១. ការកំណត់លក្ខណៈសម្បត្តិនៃស្រះ

✧នៅជិតប្រភពទឹក ឬជាស្រះដែលមិនរីងទឹកនៅរដូវប្រាំង

✧មានភ្លឺស្រះព័ទ្ធជុំវិញ ជានាមិនលិចទឹកនៅរដូវវស្សា

✧នៅជិតផ្ទះ និង មានផ្លូវចេញចូល ស្រួល។



### ២. ការរៀបចំស្រះ មុនដាក់ត្រីចិញ្ចឹម

➢ បាំងស្បៃនីឡុងជុំវិញស្រះការពារសត្រូវរបស់ត្រីចូលស្រះ

➢ បូមទឹកពង្រីងស្រះ និង បារកក់ចេញ បើទុកកក់យ៉ាងច្រើន ត្រឹមកំរាស់ ២០ សង់ទីម៉ែត្រ (២ តឹក)។

➢ បាចកំបោរស ចំនួន ពី៥ ទៅ ៧គីឡូក្រាមក្នុង១០០ម$^{២}$។ ទុកស្រះ រយៈពេលពី២ ទៅ៣ថ្ងៃ បន្ទាប់មកទើបបញ្ចូលទឹកជម្រៅ ១ ភាគ ៣ នៃជម្រៅស្រះ។

➢ ដាក់ជីលាមកគោក្រៀមចំនួនពី៣០ទៅ៥០គីឡូ/១០០ម$^{២}$

☞ ឬ លាមកមាន់/ទា ចំនួន ១០ - ១៥គីឡូ/១០០ម$^{២}$

☞ ឬ ជីកំប៉ុស្តិ៍ ចំនួន ពី ៣០ - ៥០គីឡូ/១០០ម$^{២}$

➢ ដាក់ជីអ៊ុយរ៉េ ឬ ដេ អា ប៉េ ចំនួន ០,៥គីឡូ/១០០ម$^{២}$

➢ បន្ទាប់មកបញ្ចូលទឹកឱ្យពេញស្រះ ហើយទុករយៈពេលពី៤ ទៅ ៥ថ្ងៃ សិន ទើបដាក់កូនត្រីចិញ្ចឹម។

